00293353

**Declassified to Public**
**06 September 2012**

E22/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 30 / 03 / 2009
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧/អវតក/អជសដ

**Case File/Dossier No. 001/18-07-2007/ECCC/TC**

| | |
|---|---|
| នៅចំពោះមុខ: | ចៅក្រម និល ណុន ជាប្រធាន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម យ៉ា សុខន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម ធូ មណី |
| កាលបរិច្ឆេទ: | ថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០០៩ |
| ចំណាត់ថ្នាក់នៃឯកសារ: | សម្ងាត់បំផុត |

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 30 / 01 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

---

# ដីកាស្ដីអំពីសំណើរបស់សហមេធាវីការពារក្ដីសុំតែងតាំងអ្នកជំនាញផ្នែកចិត្តវិទ្យា សម្រាប់ជនជាប់ចោទ

---

**សហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT

**ជនជាប់ចោទ**
កាំង ហ្កេកអ៊ាវ ហៅ "ឌុច"

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**
គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE
ទី ស្រីនណា
Pierre Olivier SUR
Alain WERNER
Brianne McGONIGLE
Annie DELAHAIE
Elizabeth RABESANDRATANA
Karim KHAN

**មេធាវីការពារក្ដី**
ការ សាវុត្ថ
François ROUX

E22/1

០០១/១៨ កក្កដា ២០០៧/អវតក/អជសង

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អវតក”)

**បានទទួល** សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសង អនុលោមតាម “សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចោទប្រកាន់ កាំង ហ្គេកអ៊ាវ ហៅ ឌុច” ដែលបានអានដោយផ្ទាល់មាត់ ដោយអង្គបុរេជំនុំជម្រះ នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ ហើយបានដាក់ជូនជាភាសាខ្មែរនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៨។

**បានទទួល** សំណើសុំតែងតាំងអ្នកជំនាញផ្នែកចិត្តវិជ្ជាសម្រាប់ កាំង ហ្គេកអ៊ាវ ហៅ “ឌុច” ដែលបានដាក់ជូនជាលក្ខណៈសម្ងាត់បំផុត ដែលនៅក្នុងសំណើនោះសហមេធាវីការពារក្តីស្នើសុំឲ្យមានការតែងតាំងអ្នកជំនាញផ្នែកចិត្តវិជ្ជាម្នាក់ ដើម្បីជួយដល់ជនជាប់ចោទក្នុងរយៈពេលសវនាការលើអង្គសេចក្តី (“សំណើ”)[1]។

**បានឃើញ** “របាយការណ៍កោសល្យវិច្ច័យចិត្តសាស្ត្រ” អំពីជនជាប់ចោទ ដែលបានរៀបចំធ្វើឡើងក្នុងអំឡុងដំណាក់កាលស៊ើបអង្កេត ដោយវេជ្ជបណ្ឌិត Françoise Sironi-Guilbaud និងសាស្ត្រាចារ្យកា ស៊ុនបូណាត[2]។

**បានយល់ឃើញថា** ដើម្បីវាយតម្លៃអង្គសេចក្តីនៃសំណើឲ្យបានត្រឹមត្រូវ គឺចាំបាច់ត្រូវមានការវាយតម្លៃឲ្យបានជាក់លាក់មួយអំពីស្ថានភាពចិត្តសាស្ត្ររបស់ជនជាប់ចោទ ទាក់ទិនទៅនឹងការបើកសវនាការលើអង្គសេចក្តី។

---

[1] ឯកសារ E22។

[2] ឯកសារ B1/IV។

00293355

E22/1

០០១/១៨ កក្កដា ២០០៧/អវតក/អជសជ

# ដូច្នេះ

**បង្គាប់ឱ្យ** សាស្ត្រាចារ្យ កា ស៊ុនបូណាត ធ្វើកោសល្យវិច័្ឆយទៅលើជនជាប់ចោទ បន្ទាប់ពីបានពិនិត្យមើលកំណត់ហេតុវេជ្ជសាស្ត្រដែលតម្កល់នៅមន្ទីរឃុំឃាំង អវតក រួចមក ដើម្បី ៖

ក) ធ្វើនិទស្សន៍ថាតើមានសញ្ញាណជាក់លាក់ណាមួយ ដូចដែលសហមេធាវីការពារក្តីបានលើកឡើងថា ជនជាប់ចោទនឹង "ទទួលរងការឈឺចាប់ផ្លូវចិត្តដ៏ធ្ងន់ធ្ងរ ដែលអាចបណ្តាលឱ្យមានបញ្ហាផ្នែកចិត្តសាស្ត្រដ៏ធ្ងន់ធ្ងរ ប្រសិនបើគាត់មិនបានទទួលការគាំពារផ្នែកចិត្តសាស្ត្រទេនោះ" ដែលបញ្ហានេះនឹងធ្វើឱ្យគាត់មានសម្បទាមិនគ្រប់គ្រាន់ក្នុងការចូលរួមការជំនុំជម្រះក្តី។

ខ) ប្រសិនបើមាន ត្រូវបង្ហាញអំពីកម្រិតនៃការគាំពារផ្នែកចិត្តសាស្ត្រដល់ជនជាប់ចោទសម្រាប់រយៈពេលនៃសវនាការលើអង្គសេចក្តី។

គ) ជាការចាំបាច់ ត្រូវបញ្ជាក់ប្រាប់អំពីអ្នកជំនាញផ្នែកចិត្តសាស្ត្រដ៏ត្រឹមត្រូវម្នាក់ និងអាចរកបាន ដើម្បីជួយដល់ជនជាប់ចោទ និង

ឃ) ផ្តល់សេចក្តីអង្កេតដែលពាក់ព័ន្ធផ្សេងៗទៀត។

**បង្គាប់ឱ្យ** ផ្នែកគ្រប់គ្រងតុលាការជូនដំណឹងអំពីសំណើ និងដីកានេះដល់សាស្ត្រាចារ្យ កា ស៊ុនបូណាត និងអនុញ្ញាតឱ្យគាត់ពិនិត្យមើលឯកសារមិនមែនសាធារណៈដទៃទៀត នៅក្នុងសំណុំរឿងដែលពាក់ព័ន្ធទៅនឹងបញ្ហាខាងលើ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានណែនាំ។

**បង្គាប់ឱ្យ** ប្រធានមន្ទីរឃុំឃាំង អវតក អនុញ្ញាតឱ្យសាស្ត្រាចារ្យ កា ស៊ុនបូណាត ចូលជួបជនជាប់ចោទក្នុងគោលបំណងដើម្បីអនុវត្តដីកានេះ។

E22/1

០០១/១៨ កក្កដា ២០០៧/អវតក/អជសង

**បន្ទាប់ឲ្យ** ការិយាល័យរដ្ឋបាលផ្តល់ជំនួយដល់លោកសាស្ត្រាចារ្យ កា ស៊ុនបូណាត តាមការចាំបាច់។

**បន្ទាប់ឲ្យ** សាស្ត្រាចារ្យ កា ស៊ុនបូណាត ធ្វើសេចក្តីរាយការណ៍ជូនអង្គជំនុំជម្រះសាលាដំបូង ក្នុងរយៈពេលមិនអោយលើសពីបីសប្តាហ៍បន្ទាប់ពីបានទទួលដីកានេះ។

ភ្នំពេញ ថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០០៩

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**